UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

# សិក្ខាសាលា

# ស្តីពី

# ការអនុវត្តន៍ច្បាប់ថ្មីស្តីពីបាតុកម្មដោយសន្តិវិធី

# ២៩ មីនា ២០១០

សន្ទរកថាបិទ ដោយ លោក គ្រីស្តូហ្វ ប៉េស៊ូ
តំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ឯកឧត្តម លោកជំទាវ និង លោក លោកស្រីជាទីរាប់អាន,

នេះជាថ្ងៃមួយដ៏វែងសំរាប់អ្នកទាំងអស់គ្នា ន្តែវាក៏ជាថ្ងៃមួយដែលប្រកបដោយផ្លែផ្កាផងដែរ។

កិច្ចពិភាក្សាមានលក្ខណៈផុលផុស និងបានជួយស្រាយបំភ្លឺចំណុចជាច្រើនទាក់ទងនឹងការអនុវត្តន៍ជាក់ស្តែងនៃច្បាប់សំខាន់មួយនេះ ដែលសង្ឃឹមថា នឹងជួយដល់ការអនុវត្តន៍ច្បាប់នេះ។

ដោយសារច្បាប់នេះសំខាន់ សំរាប់ការអភិវឌ្ឍន៍នៅថ្ងៃអនាគតនៃសង្គមកម្ពុជា ទើបការិយាល័យ OHCHR បានយកចិត្តទុកដាក់ខ្លាំងក្នុងការសហការជាមួយក្រសួងមហាផ្ទៃ ជួយរៀបចំច្បាប់មួយដែលល្អបំផុតតាមដែលអាចធ្វើបាន ដោយគិតគូរអំពីបរិបទនៃប្រទេសកម្ពុជា។

យើងខ្ញុំបានធ្វើការយ៉ាងជិតស្និទ្ធជាមួយ ឯកឧត្តម នុត សាអាន និងសហការីរបស់គាត់នៅទូទាំងដំណើរការនៃការតាក់តែងច្បាប់នេះ ចាប់តាំងពីឆ្នាំ២០០៥ មក ដើម្បីផ្តល់យោបល់ និងការវិភាគផ្នែកច្បាប់ ដើម្បីឲ្យសេចក្តីព្រាងច្បាប់នេះ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់។

តំលៃនៃច្បាប់មួយសំខាន់លើច្បាប់នោះផ្ទាល់ ប៉ុន្តែវាសំខាន់ និងរិតតែសំខាន់ថែមទៀតដែរលើការអនុវត្តន៍ច្បាប់នោះ។ ហើយយើងទាំងអស់គ្នាដឹងហើយថា ការអនុវត្តន៍ច្បាប់នៅប្រទេស

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

កម្ពុជា នៅមានភាពទន់ខ្សោយនៅឡើយ ដែលបណ្តាលឲ្យមានបញ្ហាគ្រប់បែបយ៉ាង និងការរំលោភសិទ្ធិមនុស្ស។ ប្រទេសកម្ពុជាបានអនុម័តច្បាប់ជាច្រើនចាប់តាំងពីឆ្នាំ១៩៧៩ មក ហើយក្នុងនោះច្បាប់ភាគច្រើន សុទ្ធតែជាច្បាប់ដែលល្អ។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ គេមិនសូវយកចិត្តទុកដាក់អនុវត្ត ឬ អនុវត្តក្នុងលក្ខណៈមួយដែលមិនត្រឹមត្រូវ។

គោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីពិនិត្យមើលបញ្ហាជាក់ស្តែងក្នុងការអនុវត្តន៍ច្បាប់នេះ តាមការដែលអាចដឹងមុន និងបង្ការបញ្ហាទាំងនោះ តាមរយៈការបង្កើតឲ្យមានជាមគ្គុទេសន៍។ នេះគឺជាគំនិតដ៏អស្ចារ្យមួយ ដែលសមនឹងទទួលបានការលើកកំពស់។

ដើម្បីអាចប្រជុំដោយសន្តិវិធី ដើម្បីពិភាក្សាដោយសេរីអំពីបញ្ហាដែលជាកង្វល់រួម អំពីថាតើគេគួររៀបចំសង្គមយ៉ាងដូចម្តេច ដើម្បីឲ្យសង្គមនោះគ្មានការភ័យខ្លាចត្រូវគេសំលាប់ វាយដំ ដាក់ពន្ធនាគារ ឬទណ្ឌកម្មឯទៀត គឺជាលក្ខខណ្ឌមួយដែលសំខាន់ចាំបាច់ក្នុងការបង្កើតសង្គមមួយ។ គ្មានអ្នកដឹកនាំណាម្នាក់ មានសមត្ថភាពមហាអស្ចារ្យអាចដោះស្រាយបញ្ហាជាច្រើន ដែលសង្គមបានជួបប្រទះនោះឡើយ - - ដូច្នេះមានតែការបើកចំហរឲ្យមានការពិភាក្សាជាមួយសង្គម ដោយការអញ្ជើញប្រជា ពលរដ្ឋឲ្យសំដែងមតិយោបល់របស់ខ្លួន ស្តាប់ពាក្យសំដីពួកគាត់ និយាយប្រាប់អំពីជីវិតរស់នៅរបស់គាត់នោះទេ ទើបអាចបង្កើតដំណោះស្រាយរយៈពេលវែង ដើម្បីឆ្លើយតបនឹងបញ្ហាទាំងនោះបាន។ ក្នុងដំណើរការនេះ តួអង្គសង្គមស៊ីវិល ដែលជារឿយៗ បានដាក់ដៃស្ទាបជីពចរសង្គម ជាអ្នករួមវិភាគមួយដ៏សំខាន់ ហើយយើងខ្ញុំសូមស្វាគមន៍ ដែលក្រសួងមហាផ្ទៃបានអញ្ជើញសង្គមស៊ីវិលចូលរួមក្នុង ការពិភាក្សានាថ្ងៃនេះ។

សេរីភាពខាងការប្រជុំ សេរីភាពក្នុងការសំដែងមតិ សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការដើរហើរ។ សេរីភាពទាំងបួននេះ គឺជាសរសរធំនៃសង្គមមួយដែលរឹងមាំ នៃដំណើរការប្រជាធិបតេយ្យមួយដែលត្រឹមត្រូវ។ ប្រសិនជាសរសរមួយឬលើសពីនេះត្រូវបាត់ សង្គមនឹងក្លាយទៅជាពិការ។ បើសង្គមនោះពិការហើយ បញ្ហាជាច្រើនអាចនឹងកើតមាន។ មានវិធីពីរដែលត្រូវដោះ ស្រាយទំនាស់ក្នុងសង្គមគឺ ៖ ការពិភាក្សានិងការសហការ ឬ អំពើហឹង្សានិងការគៀបសង្កត់។ ជំរើសរវាងដំណោះស្រាយទាំងពីរនេះ គឺដំណោះស្រាយនយោបាយ។

ព្រោះតែហេតុផលទាំងនេះហើយទើបច្បាប់សិទ្ធិមនុស្សអន្តរជាតិលើកស្ទួយតំលៃគ្រឹះនៃសិទ្ធិទាំងនេះហើយការរិតត្បិតសេរីភាពក្នុងការប្រជុំ មានតែក្នុងករណីពិសេសមួយចំនួនប៉ុណ្ណោះ។ សិទ្ធិប្រជុំក៏ដូចជាសិទ្ធិដទៃច្រើនទៀតដែរ គឺមិនដាច់ខាតនោះទេ ៖ វាត្រូវតែដោយសន្តិវិធី ហើយត្រូវតែ គោរពសិទ្ធិអ្នកដទៃ។ សិទ្ធិ និង ការទទួលខុសត្រូវ ត្រូវតែដើរទន្ទឹមគ្នា។ សិទ្ធិរបស់ខ្ញុំត្រូវបានកំណត់ដោយសិទ្ធិរបស់អ្នក។ សេរីភាពរបស់ខ្ញុំឈប់ នៅពេលដែលសេរីភាពរបស់អ្នកចាប់

ផ្ដើម ។ល។ និង ។ល។ ខ្ញុំមានសេចក្ដីរីករាយដោយឃើញថា សិក្ខាសាលានេះ និង សេចក្ដីព្រាងមគ្គុទេសន៍ស្ដីពីការ អនុវត្តន៍ច្បាប់នេះ ផ្ដល់ការណែនាំអំពីបញ្ហានេះ។

ចំណុចសំខាន់ទីពីរ ដែលសង្ឃឹមថា នឹងត្រូវបានស្រាយបំភ្លឺនៅក្នុងមគ្គុទេសន៍នេះ នោះគឺច្បាប់នេះ ក៏ដូចជាច្បាប់ដទៃទៀតដែរ គួរតែត្រូវបានអនុវត្តក្នុងលក្ខណៈមួយត្រឹមត្រូវ។ នេះ មានន័យថា ដោយមិនគិតអំពីពូជសាសន៍ សញ្ជាតិ ភេទ ជំនឿនយោបាយ ឬជំនឿសាសនា សិទ្ធិប្រជុំដោយសន្តិវិធីនេះ គួរតែទទួលបានដោយស្មើភាពគ្នាសំរាប់មនុស្សគ្រប់រូប។ សិទ្ធិនេះ មិនមែនសំរាប់តែមនុស្សដែលគិតដូចខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែក៏សំរាប់មនុស្សដែលគិតផ្សេងពីខ្ញុំផងដែរ។

ការិយាល័យយើងខ្ញុំ និង វិទ្យាស្ថាន EWMI ខិតបាននិងកំពុងប្រឹងប្រែងជួយគ្រាំទ្រដល់គំនិតផ្ដួចផ្ដើមរបស់ឯកឧត្តម នុត សាអាន ដើម្បីបង្កើតមគ្គុទេសន៍សំរាប់ការអនុវត្តន៍ច្បាប់នេះ។ ខ្ញុំសង្ឃឹមថា មគ្គុទេសន៍នេះនឹងក្លាយជាឧបករណ៍មួយដ៏សំខាន់ ហើយខ្ញុំសង្ឃឹមថានឹងបន្តកិច្ចសហប្រតិបត្តិការតទៅទៀតជាមួយក្រសួងមហាផ្ទៃ ដើម្បីជួយសម្រួលដល់ការផ្សព្វផ្សាយ ការយល់ដឹង និង ការអនុវត្តន៍ច្បាប់នេះ ដោយអាជ្ញាធរទទួលបន្ទុកអនុវត្តច្បាប់នេះ។

ជាបុគ្គលម្នាក់ដែលបាននិងកំពុងតាមដានការវិវត្តន៍នៃប្រទេសនេះជាច្រើនឆ្នាំមក ខ្ញុំទទួលស្គាល់តំលៃនៃការពិភាក្សា និងការពិគ្រោះយោបល់ជាមួយបុគ្គល និងក្រុមនានា ក្នុងសង្គមអំពីអំពើហឹង្សាក្នុងអតីតកាល ។ ខ្ញុំអបអរសាទរចំពោះការវិវឌ្ឍន៍ ដែលសំរេចបានក្នុងបញ្ហានេះ។

សិក្ខាសាលាថ្ងៃនេះគឺជាឧទាហរណ៍មួយនៃការអនុវត្តន៍ល្អ ដែលក្រសួងមហាផ្ទៃ ស្ថាប័នឯទៀត នៃរដ្ឋាភិបាល តួអង្គសង្គមស៊ីវិល និងអង្គការសហប្រជាជាតិ កំពុងច្រាក់ដៃគ្នា ពិភាក្សា និងធ្វើការទាំងអស់គ្នា ឈានទៅអនុវត្តច្បាប់ដ៏សំខាន់នេះ។ នេះជាគំរូមួយ ដែលក្រសួងមហាផ្ទៃគួរតែមាន មោទនភាព និងគួរលើកកំពស់ដល់ច្បាប់សំខាន់ៗឯទៀត នៅថ្ងៃអនាគត។

យើងខ្ញុំសង្ឃឹមរីករាយនឹងបន្តធ្វើការជាមួយក្រសួងមហាផ្ទៃ និង រដ្ឋាភិបាលក្នុងស្មារតីប្រកបដោយន័យស្ថាបនានេះ ។

សូមអរគុណច្រើន